

# ជម្រើសរបស់ម៉ាទីន

ម៉ាទីនដឹងថាគាត់ពុំគួរផឹកទឹកតែឡើយ ។ តើគាត់គួរធ្វើបែបណា ?

រូបភាពដោយ ខាធី ផើង

**ដោយ លីនសាយ ថេននើរ និង ប៊ែតថានី បាស្សូឡូមូ**

ផ្អែកទៅលើដំណើររឿងពិត

« *Be true, be true, and stand for the right* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ១៥៩* ) ។

ម៉ាទីនបានក្រោកពីដេកយឺតៗ ។ ម្ដាយគាត់បានអង្រួនស្មារបស់គាត់ ។ គាត់និយាយថា « ម៉ាទីន ដល់ម៉ោងក្រោកហើយ » ។

ម៉ាទីនបានញីភ្នែកគាត់ ។ មេឃនៅងងឹតនៅឡើយ ប៉ុន្តែគាត់ដឹងថាវាម៉ោងប៉ុន្មានហើយ ។ សមាជិកគ្រួសារគាត់ក្រោកម៉ោង ៥:៣០ នាទីរៀងរាល់ព្រឹក ដើម្បីអានគម្ពីរមរមនជាមួយគ្នា ។ វាពុំងាយស្រួលជានិច្ចក្នុងការក្រោកពីដេកនៅព្រឹកព្រលឹមពេកនោះទេ ។

ម៉ាទីនបានរំកិលខ្លួនចេញពីលើគ្រែ ហើយដើរយឺតៗទៅបន្ទប់ខាងមុខ ។ គាត់លើកដៃលាតសន្ធឹងឡើង ហើយហាមាត់ស្វាបយ៉ាងធំ ។ មើលទៅបងប្អូនប្រុសស្រីរបស់គាត់ក៏ងងុយដេកដែរ ប៉ុន្តែពួកគេបាននៅទីនោះជុំគ្នាអស់ហើយ ។

ម្នាក់ៗត្រូវអានរយៈពេលប្រាំនាទី ។ ដំបូង ម៉ាទីនចង់ត្រឡប់ទៅដេកវិញ ។ ប៉ុន្តែគាត់បន្តនៅស្ដាប់ ។ ខគម្ពីរនីមួយៗហាក់បីដូចជាធ្វើឲ្យគាត់មានអារម្មណ៍កាន់តែល្អប្រសើរឡើង ។ ដល់ពេលពួកគេអានគម្ពីរចប់ហើយ ម៉ាទីនមានអារម្មណ៍ខាងវិញ្ញាណយ៉ាងខ្លាំង ។

កម្លាំងខាងវិញ្ញាណគឺជាអ្វីមួយដែលម៉ាទីនត្រូវការចាំបាច់ជារៀងរាល់ថ្ងៃ ។ នៅក្នុងប្រទេស កេនយ៉ា មានសមាជិកសាសនាចក្រតែពីរបីនាក់ប៉ុណ្ណោះដែលមានអាយុដំណាលម៉ាទីន ហើយពួកគេទាំងអស់គ្នារស់នៅឆ្ងាយពីគ្នាណាស់ ។ បន្ទាប់ពីចប់ម៉ោងសិក្សា ម៉ាទីនបានទៅក្លឹបក្មេងប្រុស ដែលបើកដំណើរការដោយព្រះវិហារកាតូលិក ។ នាសប្ដាហ៍មួយសមាជិកក្លឹបនោះបានធ្វើដំណើរទៅបោះជំរំជាមួយគ្នា ។

ម៉ាទីនសប្បាយចិត្តណាស់ ។ គាត់បានច្រៀងចម្រៀងអំពីការបោះជំរំ ។ គាត់បានកាប់អុស ។ គាត់បានទាំងជួយបង្កាត់ភ្លើងនៅជំរំទៀតផង ។

ប៉ុន្តែនៅថ្ងៃទីពីរ មានអ្នកដឹកនាំម្នាក់បានយកតែមួយប៉ាន់មក ។ គាត់និយាយថា « យើងនឹងផឹកទឹកតែឥឡូវនេះ » ។

ក្មេងប្រុសទាំងនោះមានចិត្តរំភើបណាស់ ។ ពួកគេផឹកទឹកតែនៅផ្ទះក្នុងឱកាសពិសេសៗ ។ ពួកគេបានចាប់យកពែងរបស់ខ្លួនមក ហើយរង់ចាំអ្នកដឹកនាំនោះចាក់ទឹកតែឲ្យពួកគេ ។

ម៉ាទីនមានអារម្មណ៍ច្រួលច្របល់ក្នុងចិត្តបន្តិច ។ គាត់បានដឹងថាគាត់ពុំគួរផឹកទឹកតែឡើយ ។ ប៉ុន្តែគាត់ពុំចង់ធ្វើឲ្យមិត្តភក្តិរបស់គាត់អាក់អន់ស្រពន់ចិត្តឡើយ ។

បន្ទាប់មកគាត់បានចាំអំពីអារម្មណ៍ដែលគាត់មាន ពេលគាត់បានគោរពព្រះបញ្ញត្តិ ។ ពេលគ្រួសារគាត់បានធ្វើតាមព្យាការី ហើយអានព្រះគម្ពីរមរមនជាមួយគ្នា គាត់មានអារម្មណ៍រីករាយ ។ ពេលពួកគេពុំបានធ្វើកិច្ចការទាំងនោះ គាត់គ្មានអារម្មណ៍រីករាយឡើយ ។

ម៉ាទីនបានដឹងនូវអ្វីដែលគាត់ត្រូវធ្វើ ។

គាត់បានប្រាប់អ្នកដឹកនាំ នៅពេលអ្នកដឹកនាំនោះមកចាក់ទឹកតែឲ្យគាត់ថា « ខ្ញុំអត់ផឹកទេ សូមអរគុណ ។ ខ្ញុំមិនចង់ផឹកទឹកតែទេ » ។

អ្នកដឹកនាំនោះមើលទៅគាត់ដោយភ្ញាក់ផ្អើល ប៉ុន្តែគាត់បានឲ្យម៉ាទីនផឹកទឹកធម្មតា ខណៈដែលក្មេងទាំងអស់ផឹកទឹកតែ ។ ក្មេងប្រុសមួយចំនួនចង់ដឹងពីមូលហេតុដែលម៉ាទីនពុំផឹកទឹកតែ ប៉ុន្តែគ្មាននរណាម្នាក់សើចចំអកដល់គាត់ឡើយ ។ ម៉ាទីនមានអារម្មណ៍សប្បាយរីករាយ ។ គាត់បានដឹងថាពាក្យសម្ដីនៃប្រាជ្ញាវាងវៃធ្វើឲ្យគាត់មានរាងកាយរឹងមាំ ។ ហើយគាត់សប្បាយចិត្តដែលគាត់រឹងមាំគ្រប់គ្រាន់ដើម្បីធ្វើរឿងត្រឹមត្រូវ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

## សំណូមពរ

« ខ្ញុំនឹងថែរក្សាគំនិត ហើយនិងខ្លួនប្រាណរបស់ខ្ញុំឲ្យបរិសុទ្ធ និងពិសិដ្ឋ ហើយខ្ញុំនឹងមិនទទួលទានអ្វីដែលបង្គគ្រោះថ្នាក់ដល់ខ្ញុំឡើយ » ( បទដ្ឋានដំណឹងរបស់ខ្ញុំ ) ។

- ☐ សូមអានអំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ហើយរកមើលអ្វីដែលប្រាប់ថាវាល្អសម្រាប់អ្នក ។
- ☐ សូមធ្វើបញ្ជីអំពីគ្រឿងគ្រោះថ្នាក់ ដែលអ្នកនឹងមិនបរិភោគ ឬ ផឹកវា ។
- ☐ សូមសួរឪពុកម្ដាយអ្នក ឬ ថ្នាក់ដឹកនាំអំពីរបៀបដែលពួកគាត់រក្សាគំនិតរបស់ពួកគេបានពិសិដ្ឋ និង បរិសុទ្ធ ។
- ☐ ខ្ញុំប្ដេជ្ញាចិត្តខ្លួនខ្ញុំថា . . .

_______________________________

_______________________________